EDENBRIDGE
ASIA

ក្រុមហ៊ុន Chivas Brothers International Limited ក្រុមហ៊ុន Martell Mumm Perrier Jouet និង ក្រុមហ៊ុន The Absolut Company AB បានតែងតាំងក្រុមហ៊ុន តើណូដរីខាដ (ខេមបូដ) ឯ.ក ជាអ្នកចែកចាយផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា និងជាអ្នកមានអាជ្ញាប័ណ្ណក្នុងការចែកចាយផ្តាច់មុខផងដែរ។ ក្រុមហ៊ុន អ៊ីដិនប្រ៊ីដ អេស៊ា ផាតនើស៍ អិលធីឌី ដែលជាអ្នកតំណាងស្របច្បាប់របស់ម្ចាស់ម៉ាក CHIVAS, G.H.MUMM និង KAHLUA មានមោទភាពក្នុងការប្រកាសនូវការចេញអាជ្ញាប័ណ្ណចែកចាយផ្តាច់មុខទាំងនេះដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

លេខទំនាក់ទំនង: +855 69 753 314

CHIVAS

ដំណើររឿងនៃ Chivas Regal ជារឿងអំពីការជោគជ័យមួយ បន្ទាប់ពីបានឆ្លងកាត់នូវបញ្ហាលំបាកជាច្រើន។ ទោះបីជាមានការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិជាច្រើន ឬបានជួបប្រទះសង្គ្រាមលោកជាច្រើន ដែលធ្វើឱ្យខូចផែនការដូចជាការផ្សំលាយបញ្ចូលគ្នាមួយចំនួនតូចនៃដើមសតវត្សរ៍ទី២០ អាជីវកម្មនៅតែបន្តដំណើរការ។ ភាពតស៊ូរបស់បងប្អូន John & James Chivas បានចាប់ប្រតិបត្តិតាំងពីដើមមក ពុំមានចំណុចចុងក្រោយទេ។ យើងទាំងអស់គ្នានៅតែបន្តដំណើរនេះនាបច្ចុប្បន្ន។ នេះជាការចាប់ផ្តើមដ៏តិចតួចមែន ប៉ុន្តែពោរពេញទៅដោយសេចក្តីអង់អាច និងសក្តានុពលជាច្រើន។

- ❖ ត្រូវបានបង្កើតដោយបងប្អូនពីរនាក់គឺ James & John Chivas។
- ❖ បងប្អូនពីរនាក់នោះជាអ្នកត្រួសត្រាយសិល្បៈនៃការលាយបញ្ចូលស្រាវីស្គី។
- ❖ មានការទទួលស្គាល់ក្រោមឈ្មោះ Royal Warrant ពីម្ចាស់ក្សត្រី Victoria។
- ❖ ជាវីស្គីដ៏ប្រណិតដំបូងនៅទូទាំងពិភពលោក នៅឆ្នាំ១៩០៩។
- ❖ ពេលបច្ចុប្បន្ន មានប្រទេសលើសពី ១៥០ ដែលមានលក់ម៉ាក Chivas Regal។

G.H.MUMM
CHAMPAGNE

នៅដើមសតវត្សរ៍ទី១៩ កូនប្រុសបីនាក់របស់លោក Peter Arnold Mumm ឈ្មោះ Gottlieb, Jacobis និង Philipp បានយល់ដឹងអំពីសក្តានុពលនៃការលក់ស្រាសំប៉ាញដែលត្រូវបានផលិតឡើងក្នុងតំបន់សាំប៉ាញនៃប្រទេសបារាំង។ ដោយហេតុថាប្រទេសបារាំង និងប្រទេសអាល្លឺម៉ង់មានទំនាក់ទំនងល្អនាពេលនោះ បងប្អូនត្រកូល Mumms បានធ្វើការសម្រេចចិត្តដោយក្លាហានក្នុងការបង្កើតម៉ាកថ្មីមួយ ក្រោមនាមគ្រួសាររបស់គាត់នៅតំបន់ផលិតស្រាសាំប៉ាញ។ ពួកគាត់បានបង្កើតសាខាការិយាល័យមួយនៅ Reims ដោយមានជំនួយការពីលោក G.Heuser ដែលជាអ្នកតំណាងក្នុងស្រុក។ តាំងពីបង្កើតឡើងដំបូង គុណភាពត្រូវបានចាត់ទុកជាគន្លឹះចម្បងសម្រាប់ដៃគូគ្រប់គ្រងក្រុមហ៊ុនថ្មីមួយនេះ ដែលបានបង្កើតឡើងក្នុងឆ្នាំ១៨២៧ និងការផ្តោតលើគុណភាពនេះនៅតែជាគន្លឹះចម្បងរបស់អ្នកស្នងតំណែងបន្តបន្ទាប់ផងដែរ។ វិធីសាស្ត្រនេះ ត្រូវបានសង្ខេបចេញជាបាវចនាដែលសរសេរដោយលោក Georges Hermann Mumm គឺ "ល្អបំផុត" (Only the best)។

KAHLÚA

ដំណើររឿងនៃ Kahlúa ចាប់ផ្តើមឡើងនៅឆ្នាំ១៩៣៦ នៅពេលដែលបុរសបួននាក់ឈ្មោះ Blanco, Montalvo Lara និង បងប្អូន Alvarez បានរួមគ្នាបង្កើតឡើងនូវអ្វីមួយដ៏ប្លែក។ Kahlúa ត្រូវបានបង្កើតឡើងពីគ្រឿងផ្សំដ៏ល្អប្រណិតដែលដុះនៅជាយក្រុង Veracruz នៅប្រទេសម៉ិកស៊ិក។ ពាក្យ Kahlúa មានទំនាក់ទំនងទៅនឹងសម័យបុរាណកាល។

Kahlúa Original Coffee Liqueur ជាគ្រឿងផ្សំសំខាន់សម្រាប់ស្រាលាយ និងភេសជ្ជៈផ្សេងៗដែលពេញនិយមក្នុងនោះរួមមាន White Russian, Espresso Martini និង Mind Eraser។ វាអាចផ្លាស់ប្តូរពេលល្ងាចដ៏ធម្មតាមួយទៅជាការជួបជុំដ៏រីករាយ និងអស្ចារ្យមួយផងដែរ៕